**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

**ភាគីដាក់ឯកសារ៖** មេធាវីការពារក្តីរបស់ មាស មុត

**ដាក់ជូន៖** សហចៅក្រមស៊ើបអង្កេត

**ភាសាដើម៖** អង់គ្លេស

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៣

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 10-Mar-2014, 15:56
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ៖** សម្ងាត់បំផុត/Strictly Confidential

**ចំណាត់ថ្នាក់ប្រភេទឯកសារ៖** ប្តូរទៅជាសាធារណៈ

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖**

**ឈ្មោះមន្ត្រីកត់ត្រា៖**

**ហត្ថលេខា៖**

---

**សំណើជាបន្ទាន់របស់ មាស មុត សុំឲ្យ ក.ស.ច.ស ពិចារណាឡើងវិញ ថាតើ ក.ស.ច.ស មានយុត្តាធិការសម្រេចលើទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់ ដែរឬទេ**

---

**ដាក់ដោយ៖**

**សហមេធាវី៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark B. HARMON

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

អនុលោមតាមវិធាន ១១ វិធាន ២១ និង វិធាន ២២ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) លោក មាស មុត តាមរយៈនេះ ស្នើឲ្យសហចៅក្រមស៊ើបអង្កេតពិចារណា ឬ ពិចារណាឡើងវិញ ថាតើខ្លួនមានយុត្តាធិការបដិសេធមិនទទួលស្គាល់សហមេធាវីដោយសារតែទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់ ដែរឬទេ។ សំណើសុំនេះត្រូវធ្វើឡើងជាចាំបាច់ ដោយហេតុថាសហចៅក្រមស៊ើបអង្កេត *មិនមាន* យុត្តាធិការសម្រេចលើបញ្ហាបែបនេះទេ។ បញ្ហាទាក់ទងនឹងទំនាស់ផលប្រយោជន៍ ត្រូវសម្រេចដោយអង្គភាពគាំពារការការពារក្តី (“អ.គ.ក”) គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (“គណៈមេធាវី”) និង លើបណ្តឹងឧទ្ធរណ៍ ដោយអង្គបុរេជំនុំជម្រះ។ មេធាវីការពារក្តីស្នើសុំដាក់សំណើនេះជាភាសាអង់គ្លេសសិន ហើយអត្ថបទបកប្រែជាភាសាខ្មែរនៃសំណើនេះនឹងដាក់ជូននៅពេលក្រោយ ដោយសារតែលក្ខណៈបន្ទាន់នៃសំណើនេះ និង ដោយសារតែអង្គភាពបកប្រែភាសាមិនអាចធ្វើការបកប្រែឲ្យទាន់ពេលវេលាបាន ព្រោះតែមានអាទិភាពនៃការបកប្រែឯកសារដទៃទៀត[1]។

## I. បញ្ហាបឋមៈ ពេលវេលានៃការដាក់សំណើ និង សិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការពិចារណាលើសំណើនេះ

១. បន្ទាប់ពីការដាក់សំណើសុំការពិចារណានានារបស់មេធាវីការពារក្តី ជូនទៅ ក.ស.ច.ស ដើម្បីឆ្លើយតបទៅនឹងទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់នោះ សហចៅក្រមស៊ើបអង្កេត Harmon បានចេញសេចក្តីសម្រេចមួយក្នុងសំណុំរឿង ០០៤ ដោយលើកឡើង *នៅក្នុងចំណោមបញ្ហាជាច្រើន* ថា៖

- “សេរីភាពក្នុងការជ្រើសរើសមេធាវី គឺជាសិទ្ធិសារវ័ន្តដែលអាចត្រូវបានដាក់កំហិត តែក្នុងកាលៈទេសៈមួយចំនួនដែលត្រូវបានកំណត់និយមន័យយ៉ាងច្បាស់លាស់ ... និង អនុវត្តតាមដំណើរការដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់តែប៉ុណ្ណោះ”[2]។
- “គ្មានតួនាទីអ្វីដែលត្រូវបានចែងសម្រាប់សហចៅក្រមស៊ើបអង្កេត ឲ្យហួសពីការទទួលស្គាល់ជាផ្លូវការនូវមេធាវីនៅពេលដែលលក្ខខណ្ឌទាំងអស់ត្រូវបានបំពេញ នោះឡើយ។ ទាំងច្បាប់

[1] *សូមមើល* សារអ៊ីមែលរបស់អង្គភាពបកប្រែភាសាផ្ញើជូនមេធាវីការពារក្តី “កម្មវត្ថុៈ សំណើសុំឲ្យបកប្រែភាសា”, ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៣។

[2] ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើញត្តិ និង សារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី, ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៣, ឯកសារលេខ D122/6, កថាខណ្ឌ ៧៦។

បារាំង ទាំងច្បាប់កម្ពុជាស្តីពីគណៈមេធាវី និង ក្រមសីលធម៌វិជ្ជាជីវៈមេធាវី មិនមានចែងអំពីការផ្តល់សិទ្ធិឱ្យអាជ្ញាធរតុលាការសម្រេចអំពីថា តើសេរីភាពក្នុងការជ្រើសរើសមេធាវីរបស់ជនសង្ស័យ គួរត្រូវបានកំហិតឬអត់ នោះទេ"[3]។

- "នៅក្រោមវិធានផ្ទៃក្នុង តួនាទីក្នុងការសម្រេចថាតើសេរីភាពក្នុងការជ្រើសរើសមេធាវីត្រូវដាក់កំហិតឬអត់នោះ ត្រូវបានចែករំលែករវាងគណៈមេធាវី និង ស្ថាប័នក្នុង អ.វ.ត.ក គឺ អ.គ.ក នេះឯង"[4]។
- "មាត្រា ៩ នៃបទបញ្ជារដ្ឋបាលចែងថា បញ្ហាទំនាស់ផលប្រយោជន៍ត្រូវសម្រេចដោយ អ.គ.ក"[5]។
- "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចនានារបស់ស្ថាប័នទាំងនេះ ត្រូវដាក់ជូនអង្គបុរេជំនុំជម្រះសម្រេច អនុលោមតាមវិធាន ១១(៥) និង ២២(១)(ច)"[6]។
- "ដោយផ្អែកលើមូលដ្ឋានទាំងនេះ សហចៅក្រមស៊ើបអង្កេតមិនមានយុត្តាធិការត្រួតពិនិត្យឡើងវិញនូវទង្វើរបស់ប្រធាន អ.គ.ក នោះទេ ..."[7]។
- "តាមធម្មតា លក្ខខណ្ឌតម្រូវជាផ្លូវការសម្រាប់ការទទួលស្គាល់នឹងត្រូវបំពេញ តាមរយៈការបញ្ជាក់ថា អ.គ.ក បានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតថា មេធាវីរូបនេះបានបំពេញតាមលក្ខខណ្ឌតម្រូវទាំងអស់ ដូចបានកំណត់ដោយវិធានផ្ទៃក្នុង និង បទបញ្ជារដ្ឋបាលរបស់ អ.គ.ក។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតនឹងកម្រិតការត្រួតពិនិត្យឡើងវិញរបស់ខ្លួនទៅលើសេចក្តីសម្រេចរបស់ [សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet] ឱ្យនៅត្រឹមតែការជំទាស់តវ៉ាដែលជាប់ពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យជាសត្យានុម័តដូចជា ... អត្ថិភាពនៃទំនាស់ផលប្រយោជន៍"[8]។

២. សេចក្តីសម្រេចនេះបានលើកឡើងនូវគោលការណ៍ជាច្រើន ទាក់ទងនឹងយុត្តាធិការរបស់សហចៅ

[3] *ដូចលេខយោងខាងលើ* កថាខណ្ឌ ៧៧។

[4] *ដូចលេខយោងខាងលើ* កថាខណ្ឌ ៧៨។

[5] *ដូចលេខយោងខាងលើ*។

[6] *ដូចលេខយោងខាងលើ* កថាខណ្ឌ ៧៩។

[7] *ដូចលេខយោងខាងលើ* កថាខណ្ឌ ៨០។

[8] *ដូចលេខយោងខាងលើ* កថាខណ្ឌ ៨២។

ក្រុមស៊ើបអង្កេតលើបញ្ហាទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០៣។ គោលការណ៍ទាំងនេះ គឺមិនអាចរកបានទេ នៅពេលដែលមេធាវីការពារក្តីបានដាក់សំណើសុំការពិចារណារបស់ខ្លួន។

៣. សហចៅក្រុមស៊ើបអង្កេត Harmon បានអះអាងថា គាត់មានអំណាចឥស្សរចិត្ត "ក្នុងការពិចារណាឡើងវិញទៅលើសេចក្តីសម្រេចដែលបានចេញពីមុន ក្នុងករណីដែលមានការប្រែប្រួលកាលៈទេសៈ (អង្គហេតុថ្មី ទឡ្ហីករណ៍ថ្មី) និង ក្នុងករណីដែលសេចក្តីសម្រេចមុនមានកំហុសឆ្គង ឬអាចបណ្តាលឱ្យមានភាពអយុត្តិធម៌ ផងដែរ"[9]។ សហចៅក្រុមស៊ើបអង្កេត Harmon មិនទាន់បានចេញសេចក្តីសម្រេចផ្លូវការណាមួយ ស្តីពីទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់នៅឡើយទេ[10] បើទុកជាការពិតនោះ គឺគាត់កំពុងតែអនុវត្តយុត្តាធិការ ដែលហាក់ដូចជាគាត់បានចេញសេចក្តីសម្រេចមួយរួចទៅហើយក្តី។ ចំណុចនេះត្រូវបានស្តែងឡើង តាមរយៈដីកាសម្រេចកំណត់ពេលវេលាផ្សេងៗរបស់គាត់ ដូចជា ដីកាសម្រេចរបស់គាត់ហាមឃាត់សហមេធាវីការពារក្តីមិនឱ្យប្រាស្រ័យទាក់ទងជាមួយកូនក្តីរបស់ពួកគេ និង តាមរយៈលិខិតរបស់គាត់ផ្ញើជូនសហមេធាវីជូនដំណឹងពួកគេថា គាត់នឹងមិនពិចារណាលើសំណើសុំការពិចារណាលើអង្គច្បាប់នានារបស់មេធាវីការពារក្តីនោះទេ រហូតដល់ពេលដែលបញ្ហាការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍ដែលត្រូវបានលើកឡើងដោយអតីតសហព្រះរាជអាជ្ញាអន្តរជាតិ Andrew Cayley ត្រូវបានដោះស្រាយរួចរាល់សិន។

៤. ដោយសារតែសហចៅក្រុមស៊ើបអង្កេតមិនមានយុត្តាធិការសម្រេចលើបញ្ហាទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់ និង ដោយសារតែសេចក្តីសម្រេចដែលមានប្រសិទ្ធភាពរបស់សហចៅក្រុមស៊ើបអង្កេត Harmon ក្នុងការអនុវត្តយុត្តាធិការនេះទាំងមានកំហុសឆ្គងនោះ សហចៅក្រុមស៊ើបអង្កេតមានអំណាចឥស្សរចិត្ត ហើយជាការពិត មានកាតព្វកិច្ចនៅក្នុងផលប្រយោជន៍យុត្តិធម៌ ដើម្បីធ្វើការពិចារណាឡើងវិញ និង សម្រេចច្រានចោលសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះ។ ការខកខានមិនបានពិចារណាឡើងវិញ លើការអនុវត្តយុត្តាធិការរបស់សហចៅក្រុមស៊ើបអង្កេត Harmon អាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់លោក មាស មុត ក្នុងការជ្រើសរើសមេធាវី

---

[9] *ដូចលេខយោងខាងលើ* កថាខណ្ឌ ៤៤។

[10] កន្លងមក សហចៅក្រុមស៊ើបអង្កេត Harmon បានបំពេញកិច្ចតែម្នាក់ឯងពាក់ព័ន្ធនឹងបញ្ហាទាំងអស់ ដែលទាក់ទងនឹងទំនាស់ផលប្រយោជន៍ដែលត្រូវបានលើកឡើងដោយអតីតសហព្រះរាជអាជ្ញាអន្តរជាតិ Cayley។

ការពារក្តីតាមជម្រើសរបស់គាត់ផ្ទាល់ និង ប្រាស្រ័យទាក់ទងជាមួយមេធាវីរបស់គាត់។

៥. បញ្ហានានាស្តីពីយុត្តាធិការ អាចនឹងត្រូវបានលើកឡើងនៅដំណាក់កាលណាមួយក្នុងកិច្ចដំណើរការនីតិវិធីបាន ក្នុងករណីដែលសេចក្តីសម្រេចមួយលើយុត្តាធិការ អាចបញ្ចប់កិច្ចដំណើរការនីតិវិធី[11]។ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក មាស មុត នឹងមិនអាចត្រូវបានបញ្ចប់ទេ បើទោះបីជាសហចៅក្រមស៊ើបអង្កេតរកឃើញថា ខ្លួនពុំមានយុត្តាធិការសម្រេចលើបញ្ហាទំនាស់ផលប្រយោជន៍

[11] *សំណុំរឿង កាំង ហ្គេកអ៊ាវ* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក, សាលដីកា ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ F28 កថាខណ្ឌ ៣០-៣៥។ យោងតាមកថាខណ្ឌ ៣១៖ “គោលគំនិតនៃអញ្ញត្រកម្មបឋមអំពីយុត្តាធិការត្រូវបានបកស្រាយថា គឺជាចរិតលក្ខណៈនៃវិការៈផ្នែកយុត្តាធិការដែលរងការជំទាស់។ បញ្ហាកង្វះយុត្តាធិការដែលបានលើកឡើង អាចមានលក្ខណៈជាវិការៈដែលមិនមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី *ទាំងស្រុងទេ* (*in limine*) ឧទាហរណ៍ដូចជា តុលាការផ្សេងទៀតមានសមត្ថកិច្ចជំនុំជម្រះលើករណីនេះ។ ដូច្នេះ បន្ទាប់ពីចាប់ផ្តើមសវនាការលើអង្គសេចក្តី (ឬបន្ទាប់ពីផុតអាជ្ញាយុកាលផ្សេងទៀត) ភាគីមិនអាចលើកឡើងនូវការជំទាស់ទៅនឹងវិការៈផ្នែកយុត្តាធិការបានទេ។ មូលហេតុនៃការហាមឃាត់នេះ គឺតុលាការចាត់ទុកថា ភាគីទាំងអស់បានយល់ព្រមទៅលើយុត្តាធិការរបស់តុលាការ ដោយសារវិការៈត្រូវបានបញ្ចប់តាមរយៈការប្រព្រឹត្តទៅនៃដំណើរការនីតិវិធី។ ប៉ុន្តែ ប្រសិនបើកង្វះយុត្តាធិការដែលបានលើកឡើងនោះ មានអានុភាពធ្វើឲ្យកិច្ចដំណើរការនីតិវិធីក្លាយជាមោឃៈបាន នោះភាគីអាចលើកឡើងនូវការជំទាស់ទៅនឹងវិការៈផ្នែកយុត្តាធិការបានគ្រប់ពេលវេលា ក្នុងអំឡុងពេលនៃដំណើរការនីតិវិធី រួមទាំងនៅដំណាក់កាលបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលផងដែរ។ ទោះបីជានីតិវិធីព្រហ្មទណ្ឌកម្ពុជាពុំមានចែងឲ្យបានច្បាស់លាស់អំពីភាពខុសគ្នានេះ នៅក្នុងវិការៈផ្នែកយុត្តាធិការក៏ដោយ ក៏ច្បាប់បារាំងដែលអាចយកមកប្រើសម្រាប់ធ្វើការបកស្រាយច្បាប់កម្ពុជាបាននោះ បង្ហាញថា [កាលបរិច្ឆេទដែលមានចែងក្នុងវិធានផ្ទៃក្នុង] មិនគួរត្រូវបានយកមកអនុវត្តលើការជំទាស់ទៅនឹងយុត្តាធិការ ដែលអាចមោឃៈកិច្ចដំណើរការនីតិវិធីនោះទេ”។ ចំណុចនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងយុត្តាធិការតុលាការសហព័ន្ធសហរដ្ឋអាមេរិកដែលថា “ការជំទាស់ទាំងឡាយទៅនឹងបញ្ហាយុត្តាធិការអាចត្រូវបានលើកឡើងជាលើកដំបូង ដោយយឺតពេលវេលាបន្តិចនៅក្នុងកិច្ចដំណើរការនីតិវិធី ...។ បញ្ហាយុត្តាធិការអាចត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ដោយភាគីណាមួយ ឬ តាមគំនិតផ្តួចផ្តើមរបស់តុលាការ ទោះបីជាបញ្ហាទាំងនេះមិនទាន់ត្រូវបានលើកឡើងនៅក្នុងសវនាការ ឬ នៅក្នុងបណ្តឹងឧទ្ធរណ៍មុនៗក៏ដោយ។ ជាញឹកញាប់ នៅក្នុងសេចក្តីសម្រេចនានានៃយុត្តាធិការសហព័ន្ធ ដើម្បីឲ្យបញ្ហាមួយដែលលើកឡើងជាលើកដំបូងនៅចំពោះមុខតុលាការកំពូលសហរដ្ឋអាមេរិក ត្រូវបានយកទៅពិចារណាលើអង្គសេចក្តីរបស់វា និង ចេញសេចក្តីសម្រេចដែលនាំឲ្យការពិភាក្សាលើសម្អាងហេតុទាំងអស់ ដែលបានធ្វើឡើងនៅតុលាការជាន់ទាបលែងមានន័យអ្វីទាំងអស់”។ Martha A. Field, *លក្ខណៈមិនពិតប្រាកដនៃយុត្តាធិការសហព័ន្ធ*, 22 WM. & MARY L. REV. 683 (1981) ដែលអាចរកបាននៅលើគេហទំព័រ៖ http://scholarship.law.wm.edu/wmlr/vol22/iss4/5។

ដែលត្រូវបានចោទប្រកាន់នេះក៏ដោយ។ ប៉ុន្តែ កិច្ចដំណើរការនីតិវិធីលើបញ្ហាទំនាស់ផលប្រយោជន៍ *អាចនឹង* ត្រូវបានបញ្ចប់ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតរកឃើញថា ខ្លួនពុំមានយុត្តាធិការទេនោះ។ ដូចដែលបានលើកទឡ្ហីករណ៍នៅក្នុងកថាខណ្ឌ ២៦ ដល់ ៣១ ខាងក្រោម ស្ថាប័នដែលមានសិទ្ធិអំណាចត្រឹមត្រូវក្នុងការសម្រេចលើទំនាស់ផលប្រយោជន៍ (អ.គ.ក និង គណៈមេធាវី) បានសម្រេចរួចមកហើយថា ពុំមានទំនាស់កើតឡើងនោះទេ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតយល់ឃើញថា សំណើសុំនេះមិនអាចត្រូវបានលើកឡើងថា ជាសំណើសុំដាច់ដោយឡែកនៅដំណាក់កាលនេះបានទេ នោះជាជម្រើសផ្សេងទៀត មេធាវីការពារក្តីសូមគោរពស្នើសុំដាក់សំណើនេះ ជាសំណើសុំការពិចារណាបន្ថែមទៅលើសំណើរបស់ខ្លួនស្តីពីទំនាស់ផលប្រយោជន៍ ដែលបានដាក់ជូនរួចមកហើយ ដូចដែលបានអនុញ្ញាតដោយយុត្តិសាស្ត្ររបស់អ.វ.ត.ក ស្រាប់[12]។

## II. ប្រវត្តិសាវតា

៦. នៅថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១២ លោក មាស មុត បានស្នើសុំឲ្យ អ.គ.ក ចាត់តាំងលោក អាង ឧត្តម និង លោក Michael G. Karnavas ធ្វើជាសហមេធាវីរបស់គាត់[13]។ លោក មាស មុត បានផ្តល់ជូន អ.គ.ក នូវលិខិតលះបង់សិទ្ធិទៅលើទំនាស់ផលប្រយោជន៍ជាសក្តានុភូត ដែលអាចនឹងកើតមានឡើង ដោយសារតែសហមេធាវីទាំងនេះបានធ្វើជាតំណាងការពារឲ្យលោក អៀង សារី[14]។

[12] អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចនាពេលថ្មីៗនេះថា "ដំណើរការសម្រាប់ការទទួលយកសំណើសុំការពិចារណាបន្ថែមគឺជារឿងធម្មតានៅកម្រិតអន្តរជាតិ ដោយហេតុថា ការអនុញ្ញាតសម្រាប់ការទទួលយកឯកសារបែបនេះ ត្រូវបានស្នើសុំនៅមុន ឬ នៅពេលដាក់ឯកសារនោះតែម្តង"។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា សារៈសំខាន់នៃបញ្ហាទាំងឡាយនៅចំពោះមុខបានអនុញ្ញាតឲ្យមានការទទួលយកសំណើសុំការពិចារណាបន្ថែមដើម្បីជាប្រយោជន៍យុត្តិធម៌។ *សូមមើល រឿងក្តីរបស់ នួន ជា និង ជនជាប់ចោទដទៃទៀត*, សំណុំរឿងលេខ ០០២-១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(២៨), សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២, ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៣, ឯកសារលេខ E284/4/8 កថាខណ្ឌ ១៣-១៤។

[13] ការកំណត់លើការអះអាងអំពីភាពក្រីក្ររបស់លោក និង សេចក្តីសម្រេចទៅលើសំណើសុំឲ្យបើកប្រាក់កម្រៃជូនសហមេធាវីក្រោមគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក, ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១១, ឯកសារលេខ D56/11 កថាខណ្ឌ ១។

[14] *សូមមើល* សំណើសុំការអនុញ្ញាតបន្ថែមចំនួនទំព័រដែលបានកំណត់ និង សំណើសុំការពិចារណារបស់សហមេធាវី ស្តីពីទំនាស់ផលប្រយោជន៍ជាសក្តានុភូតនៅក្នុងការធ្វើជាតំណាងការពារឲ្យលោក មាស មុត ក្នុងសំណុំរឿង ០០៣, ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០១៣, ឯកសារលេខ D56/4/1 ឧបសម្ព័ន្ធ ក។

៧. នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១២ ប្រធាន អ.គ.ក លោក Isaac Endeley បានជួបជាមួយលោក មាស មុត ដើម្បីពិភាក្សាអំពីសំណើនេះ[15]។

៨. នៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១២ លោក Endeley បានតែងតាំងលោក អាង ឧត្តម និង លោក Michael G. Karnavas ឲ្យធ្វើជាសហមេធាវីការពារក្តីរបស់លោក មាស មុត ដោយឈរលើមូលដ្ឋាននៃ *ការផ្តល់សេវាកម្មច្បាប់មិនយកកម្រៃ* ដោយមានការយល់ឃើញថា សហមេធាវីអាចនឹងទទួលបានប្រាក់កម្រៃដោយប្រតិសកម្ម នៅក្រោមគម្រោងជំនួយសេវាផ្លូវច្បាប់របស់ អ.វ.ត.ក ក្នុងករណីដែលលោក មាស មុត ត្រូវបានកំណត់ថាជាជនក្រីក្រមែននោះ[16]។ នៅថ្ងៃដដែលនេះ អ.គ.ក បានចេញសេចក្តីប្រកាសព័ត៌មានមួយដោយបញ្ជាក់ថា "នៅក្នុងការតែងតាំងនេះ អ.គ.ក បានពិចារណាលើការចង់បានជាក់ស្តែងរបស់ជនសង្ស័យ បទពិសោធន៍ទូទៅរបស់មេធាវីក្នុងវិស័យច្បាប់មនុស្សធម៌ និង ឧក្រិដ្ឋកម្មអន្តរជាតិ កម្រិតនៃការយល់ដឹងរបស់ពួកគេទៅលើវិធានជាមូលដ្ឋាន ទម្លាប់អនុវត្តន៍ និង នីតិវិធីនៅ អ.វ.ត.ក ចំណេះដឹងរបស់ពួកគេអំពីបរិបទប្រវត្តិសាស្ត្រ និង នយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ និង ការលះបង់សិទ្ធិលើទំនាស់ផលប្រយោជន៍ទាំងអស់ដែលអាចកើតមានឡើង[17]។

៩. នៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១២ លោក Endeley បានដាក់លិខិតមួយច្បាប់ជូនសហចៅក្រមស៊ើបអង្កេត ដោយជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេត អំពីសេចក្តីសម្រេចរបស់គាត់ក្នុងការតែងតាំងសហមេធាវី ដោយឈរមូលដ្ឋាននៃ*ការផ្តល់សេវាកម្មច្បាប់មិនយកកម្រៃ* ក្នុងពេលកំពុងរង់ចាំការសម្រេចសេចក្តីអំពីភាពក្រីក្រ។ លោក Endeley បានលើកឡើង *នៅក្នុងចំណោមបញ្ហាជាច្រើន* ថា៖

> ខ្ញុំបានជួបជាមួយលោក មាស មុត កាលពីថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១២ ដើម្បីសួរបញ្ជាក់អំពីជម្រើសរបស់គាត់ក្នុងការជ្រើសរើសសហមេធាវី។ គាត់បានបញ្ជាក់បន្ថែមថា គាត់មានបំណងជ្រើសរើសយកលោក អាង ឧត្តម និង លោក Michael G. Karnavas

---

[15] ការកំណត់លើការអះអាងអំពីភាពក្រីក្ររបស់លោក និង សេចក្តីសម្រេចទៅលើសំណើសុំឲ្យបើកប្រាក់កម្រៃជូនសហមេធាវីក្រោមគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក, ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៣, ឯកសារលេខ D56/11 កថាខណ្ឌ ១។

[16] *ដូចលេខយោងខាងលើ* កថាខណ្ឌ ៥។

[17] សេចក្តីប្រកាសព័ត៌មាន, លោក អាង ឧត្តម និង លោក Michael G. Karnavas ត្រូវបានចាត់តាំងជាមេធាវីការពារក្តី តំណាងឲ្យជនសង្ស័យមួយរូបនៅក្នុងសំណុំរឿង ០០៣, ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៣។

ឲ្យធ្វើជាតំណាងការពារក្ដីរបស់គាត់ ហើយថា គាត់បានធ្វើសេចក្ដីសម្រេចចិត្តនេះដោយសេរី និងថា គាត់បានដឹងថាមេធាវីដដែលនេះបានធ្វើជាតំណាងការពារឲ្យបុគ្គលម្នាក់ទៀតរួចទៅហើយ នៅចំពោះមុខ អ.វ.ត.ក។ គាត់បានបញ្ជាក់បន្ថែមទៀតថា គាត់បានយល់ដឹងអំពីអត្ថន័យនៃលិខិតលះបង់សិទ្ធិដែលគាត់បានចុះហត្ថលេខា ទាក់ទងនឹងទំនាស់ផលប្រយោជន៍ជាសក្ដានុភូតណាមួយ ជាមួយនឹងបុគ្គលផ្សេងទៀត ដែលតំណាងដោយមេធាវីរបស់គាត់ ...។ នៅក្នុងការពិនិត្យទៅលើសំណើសុំឲ្យចាត់តាំងមេធាវីការពារក្ដី ខ្ញុំបានពិចារណាទៅលើការចង់បានជាក់ស្ដែងរបស់លោក មាស មុត បទពិសោធន៍ទូទៅរបស់មេធាវីក្នុងវិស័យច្បាប់មនុស្សធម៌ និង ឧក្រិដ្ឋកម្មអន្តរជាតិ កម្រិតនៃការយល់ដឹងរបស់ពួកគេទៅលើវិធានជាមូលដ្ឋាន ទម្លាប់អនុវត្តន៍ និង នីតិវិធីនៅ អ.វ.ត.ក ចំណេះដឹងរបស់ពួកគេអំពីបរិបទប្រវត្តិសាស្ត្រ និង នយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ និងការលះបង់សិទ្ធិលើទំនាស់ផលប្រយោជន៍ទាំងអស់ដែលអាចកើតមានឡើង[18]។

១០. នៅថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានដាក់សំណើមួយច្បាប់ទៅ ក.ស.ច.ស ដោយស្នើសុំឲ្យច្រានចោលការតែងតាំងសហមេធាវីការពារក្ដី ដោយយោងលើមូលដ្ឋានទំនាស់ផលប្រយោជន៍មិនអាចផ្សះផ្សាបាន ដោយសារតែសហមេធាវីទាំងពីរបានធ្វើជាតំណាងការពារឲ្យលោក អៀង សារី នៅក្នុងពេលដំណាលគ្នានេះ (“សំណើរបស់ Cayley”)[19]។ នៅក្នុងសំណើរបស់គាត់ សហព្រះរាជអាជ្ញាអន្តរជាតិបានចម្លងជូន អ.គ.ក ប៉ុន្តែ មិនបានលើកឡើងអំពីបញ្ហានេះនៅចំពោះមុខ អ.គ.ក ឬ នៅចំពោះមុខគណៈមេធាវីកម្ពុជានោះទេ។

១១. នៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត Harmon បានចេញសេចក្ដីសម្រេច និង ដីកាសម្រេចអំពីការកំណត់ពេលវេលាដោយ៖ **ក)** បង្គាប់សហមេធាវីមិនឲ្យប្រាស្រ័យទាក់ទងជាមួយលោក មាស មុត រហូតទាល់តែសេចក្ដីសម្រេចលើការបញ្ជាក់អំពីការតែងតាំងរបស់ពួកគេត្រូវបានសម្រេចរួចរាល់សិន **ខ)** បង្គាប់ឲ្យពួកគេបង្ហាញលិខិតលះបង់សិទ្ធិលើទំនាស់ផលប្រយោជន៍ជាសក្ដានុភូត ដែលបានចុះហត្ថលេខាដោយលោក អៀង សារី និង លោក មាស មុត

---

[18] ការតែងតាំងសហមេធាវីឲ្យធ្វើជាតំណាងឲ្យលោក មាស មុត, ជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៣, ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១២, ឯកសារលេខ D56, កថាខណ្ឌ ៤ និង កថាខណ្ឌ ១០។

[19] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យច្រានចោលការតែងតាំងសហមេធាវីចាត់តាំង ដោយយោងលើមូលដ្ឋានទំនាស់ផលប្រយោជន៍មិនអាចផ្សះផ្សាបាន, ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០១២, ឯកសារលេខ D56/1។

គ) ផ្តល់ជូនសហមេធាវីនូវដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ក្នុងគោលបំណងធ្វើការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និង ឃ) អញ្ជើញសហមេធាវីការពារក្តីឲ្យដាក់ចម្លើយ និង ឲ្យ ក.ស.ព ដាក់ការឆ្លើយតប[20]។

១២. នៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០១៣ សហមេធាវីបានឆ្លើយតបនឹងសំណើរបស់ Cayley[21]។ សហមេធាវីបានអះអាងថា មិនមានទំនាក់ទំនងអង្គហេតុជិតដិតរវាងទង្វើដែលបានចោទប្រកាន់មកលើលោក អៀង សារី និង លោក មាស មុត នោះទេ ហើយក៏មិនមានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ប្រឆាំងនឹងការចាត់តាំងសហមេធាវីនៅក្នុងសំណុំរឿង ០០៣ នោះដែរ។

១៣. នៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឲ្យ ក.ស.ច.ស ធ្វើការកំណត់កាលបរិច្ឆេទឡើងវិញដើម្បីដាក់សំណើសុំការពិចារណានានា ដោយសារតែកាលៈទេសៈមួយចំនួនមានការប្រែប្រួល បណ្តាលមកពីមរណភាពរបស់លោក អៀង សារី កាលពីថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៣ កន្លងទៅនេះ[22]។ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឲ្យផ្តល់ "ពេលវេលាមួយសមស្រប" ដើម្បីដាក់សំណើដែលបានកែប្រែ និង ស្នើសុំឲ្យកំណត់កាលបរិច្ឆេទជាថ្មីដើម្បីអនុញ្ញាតឲ្យសហមេធាវីដាក់ចម្លើយ និង ឲ្យ ក.ស.ព ដាក់ការឆ្លើយតប។

១៤. នៅថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត Harmon បានចេញសេចក្តីសម្រេច និង ចេញដីកាកំណត់ពេលវេលា ថ្មីមួយ កត់សម្គាល់ថា កាលៈទេសៈមួយចំនួនបានប្រែប្រួល ចាប់តាំងពីពេលលោក អៀង សារី បានទទួលមរណភាព ស្នើសុំឲ្យ ក.ស.ព ដាក់សំណើសុំការពិចារណានានាជាថ្មីឡើងវិញ និង លើកឡើងថា សហមេធាវីអាចដាក់ចម្លើយ ហើយ ក.ស.ព

---

[20] សេចក្តីសម្រេច និង ដីកាកំណត់កាលបរិច្ឆេទទាក់ទងនឹងសំណើសុំការតែងតាំងសហមេធាវីចាត់តាំង, ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៣, ឯកសារលេខ D56/3។ នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៣ ការកំណត់កាលបរិច្ឆេទសម្រាប់ការដាក់សំណើសុំការពិចារណាត្រូវបានពន្យារ តាមរយៈដីកាកំណត់កាលបរិច្ឆេទឡើងវិញ ទាក់ទងនឹងសំណើសុំការតែងតាំងសហមេធាវីចាត់តាំង, ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៣, ឯកសារលេខ D56/4។

[21] សំណើសុំការអនុញ្ញាតបន្ថែមចំនួនទំព័រដែលបានកំណត់ និង សំណើសុំការពិចារណារបស់សហមេធាវីការពារក្តី ស្តីពីទំនាស់ផលប្រយោជន៍ជាសក្តានុភូតនៅក្នុងការតំណាងការពារឲ្យលោក មាស មុត ក្នុងសំណុំរឿង ០០៣, ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០១៣, ឯកសារលេខ D56/4/1។

[22] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យកំណត់កាលបរិច្ឆេទជាថ្មីសម្រាប់ការដាក់សំណើសុំការពិចារណានានា, ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៣, ឯកសារលេខ D56/4/3។

អាចដាក់ការឆ្លើយតបបាន[23]។

១៥. នៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើសុំការពិចារណាបន្ថែមរបស់ខ្លួនដោយធ្វើការជំទាស់ជាថ្មីថា ការចាត់តាំងសហមេធាវីគួរតែត្រូវបានច្រានចោលដោយសារតែបញ្ហាទំនាស់ផលប្រយោជន៍ ដែលកើតចេញការធ្វើជាតំណាងការពារក្ដីរបស់ពួកគេឱ្យលោក អៀង សារី កាលពីពេលកន្លងទៅ[24]។

១៦. នៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៣ សហមេធាវីបានដាក់ចម្លើយរបស់ខ្លួនតបទៅនឹងសំណើសុំការពិចារណាបន្ថែម[25]។ សហមេធាវីបានអះអាងជាថ្មីថា មិនមានទំនាស់ផលប្រយោជន៍ណាមួយកើតឡើង ដែលអាចរារាំងពួកគេមិនឱ្យមានលទ្ធភាពធ្វើជាតំណាងរបស់លោក មាស មុត ឱ្យអស់ពីលទ្ធភាពនោះទេ។

១៧. នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៣ លោក Endeley បានចេញសេចក្ដីសម្រេចមួយដែលបញ្ជាក់ថា លោក មាស មុត មិនមែនជាជនក្រីក្រទេ ហើយការបើកប្រាក់កម្រៃទាំងអស់ ឬ មួយផ្នែក ជូនសហមេធាវីក្រោមគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក នឹងមិនត្រូវបានអនុញ្ញាតឡើយ[26]។

១៨. នៅថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត Harmon បានចេញសេចក្ដីសម្រេចមួយពន្យារកាលបរិច្ឆេទ សម្រាប់ការដាក់ការឆ្លើយតបចំពោះការចោទប្រកាន់អំពីបញ្ហាទំនាស់ផលប្រយោជន៍ ដោយរង់ចាំការសម្រេចពីលោក មាស មុត ទាក់ទងនឹងតំណាងតាមផ្លូវច្បាប់របស់គាត់ជាមុនសិន[27] ។

---

[23] សេចក្ដីសម្រេច និង ដីកាកំណត់កាលបរិច្ឆេទឡើងវិញជាលើកទីពីរ ទាក់ទងនឹងសំណើសុំការតែងតាំងសហមេធាវីចាត់តាំង, ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១៣, ឯកសារលេខ D56/5។

[24] សំណើសុំការពិចារណាបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្ដីពីទំនាស់ផលប្រយោជន៍របស់សហមេធាវីចាត់តាំង, ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៣, ឯកសារលេខ D56/7។

[25] សំណើសុំការអនុញ្ញាតបន្ថែមចំនួនទំព័រដែលបានកំណត់ និង ចម្លើយរបស់សហមេធាវីតបទៅនឹងសំណើសុំការពិចារណាបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្ដីពីទំនាស់ផលប្រយោជន៍របស់សហមេធាវីចាត់តាំង, ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៣ ឯកសារលេខ D56/9។

[26] ការកំណត់លើការអះអាងអំពីភាពក្រីក្ររបស់លោក និង សេចក្ដីសម្រេចទៅលើសំណើសុំឱ្យបើកប្រាក់កម្រៃជូនសហមេធាវីក្រោមគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក, ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១១, ឯកសារលេខ D56/11។

[27] សេចក្ដីសម្រេចលើការប្រាស្រ័យទាក់ទងរវាងសហមេធាវីចាត់តាំង និង ជនសង្ស័យ, ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៣ ឯកសារលេខ D56/12។

១៩. នៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៣ មេធាវីការពារក្ដីបានប្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងការកំណត់របស់ អ.គ.ក ដែលថា លោក មាស មុត មិនមែនជាជនក្រីក្រ[28]។

២០. នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត Harmon បានចេញសេចក្ដីសម្រេចមួយដែលរកឃើញថា មានកង្វះខាតនៅក្នុងនីតិវិធីដែលកំណត់អំពីភាពក្រីក្រនេះ ហើយខ្លឹមសារនៃការសម្រេចមានភាពខ្វះចន្លោះ។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតបានប្រកាសលុបចោលការកំណត់អំពីភាពក្រីក្ររបស់ អ.គ.ក និង បង្គាប់ឲ្យ អ.គ.ក វាយតម្លៃឡើងវិញលើបញ្ហាភាពក្រីក្ររបស់លោក មាស មុត[29]។

២១. នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៣ អ.គ.ក បានចេញនូវការកំណត់ថ្មី ដែលរកឃើញថា លោក មាស មុត គឺជាជនក្រីក្រ ហើយការផ្ដល់ជំនួយផ្នែកច្បាប់របស់គាត់ គួរត្រូវបានចំណាយតាមរយៈគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក។ លោក Endeley បានលើកឡើងថា៖ "ខ្ញុំបានដឹងថា លោក អាង ឧត្ដម និង លោក Michael G. Karnavas នៅតែត្រូវបានហាមឃាត់ដោយដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត មិនឲ្យទំនាក់ទំនងជាមួយលោក រហូតដល់មានការជូនដំណឹងបន្ថែម។ តាមរយៈនេះ ខ្ញុំកំពុងតែគោរពស្នើសុំលោកចៅក្រមឲ្យពិចារណាលើកចោលដីកាសម្រេចនេះ តាមលក្ខណៈសមស្រប ដើម្បីអនុញ្ញាតឲ្យសហមេធាវីអាចពិគ្រោះយោបល់ជាមួយ

---

[28] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការកំណត់លើការអះអាងអំពីភាពក្រីក្រ និង សេចក្ដីសម្រេចលើសំណើសុំឲ្យបើកប្រាក់កម្រៃសម្រាប់សហមេធាវី ក្រោមគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក, ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៣, ឯកសារលេខ D56/11/2។ មេធាវីការពារក្ដីបានប្ដឹងឧទ្ធរណ៍ ដោយមិនទទួលបាននូវឯកសារគាំទ្រដែល អ.គ.ក បានប្រើប្រាស់ដើម្បីឈានដល់ការធ្វើសេចក្ដីសម្រេចរបស់ខ្លួន។ នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១៣ អ.គ.ក បានផ្ដល់ជូនមេធាវីការពារក្ដីនូវរបាយការណ៍ចំនួនពីរច្បាប់ដែលរៀបចំឡើងដោយ Deloitte និង Touche ព្រមទាំងឧបសម្ព័ន្ធមួយច្បាប់នៃអត្ថបទសារព័ត៌មាន។ របាយការណ៍ទាំងពីរនេះត្រូវបានកោសលុបមួយផ្នែកតូច។ នៅថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០១៣ មេធាវីការពារក្ដីបានដាក់សំណើសុំការពិចារណាបន្ថែម រួមទាំងឧបសម្ព័ន្ធបន្ថែមដែលបានកែប្រែមួយច្បាប់។ សំណើសុំការពិចារណាបន្ថែមរបស់ មាស មុត ដើម្បីគាំទ្របណ្ដឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងការកំណត់លើការអះអាងអំពីភាពក្រីក្រ និង សេចក្ដីសម្រេចលើសំណើសុំឲ្យបើកប្រាក់កម្រៃរបស់មេធាវីការពារក្ដី នៅក្រោមគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក, ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០១៣, ឯកសារលេខ D56/11/4 និង ឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ។

[29] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការកំណត់របស់ អ.គ.ក លើបញ្ហាភាពក្រីក្ររបស់ មាស មុត, ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៣, ឯកសារលេខ D56/11/7។

លោក ទាក់ទងនឹងសេចក្តីសម្រេចបច្ចុប្បន្ននេះ”[30]។

២២. នៅចន្លោះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៣ និង ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១៣ មេធាវីការពារក្តី បានដាក់សំណើសុំការពិចារណាចំនួន ១៤ ច្បាប់ជូន ក.ស.ច.ស ឱ្យដោះស្រាយបញ្ហាខ្លឹមសារច្បាប់ និង បញ្ហានីតិវិធីសំខាន់ៗមួយចំនួន[31]។

---

[30] ការកំណត់ជាចុងក្រោយលើការអះអាងអំពីភាពក្រីក្ររបស់លោក និង សេចក្តីសម្រេចលើសំណើសុំឱ្យបើកប្រាក់កម្រៃរបស់មេធាវីការពារក្តី នៅក្រោមគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក, ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៣, ឯកសារលេខ D56/13 កថាខណ្ឌ ១២។

[31] សំណើរបស់ មាស មុត ស្នើសុំចូលត្រួតពិនិត្យមើលសំណុំរឿង និង ចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ, ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៣ ឯកសារលេខ D82។ សំណើរបស់ មាស មុត ស្នើសុំព័ត៌មានទាក់ទងនឹងវិធីសាស្ត្រ និង មធ្យោបាយស៊ើបអង្កេតរបស់ ក.ស.ច.ស, ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១៣ ។ សេចក្តីជូនដំណឹងរបស់លោក មាស មុត អំពីការជំទាស់ទៅនឹងការចូលរួមពាក់ព័ន្ធណាមួយបន្ថែមទៀតរបស់ Stephen Heder នៅក្នុងសំណុំរឿង ០០៣ និង សំណើសុំឱ្យផ្តល់លទ្ធផលការងាររបស់ David Boyle, ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ ២០១៣។ សេចក្តីជូនដំណឹងរបស់លោក មាស មុត អំពីការជំទាស់ទៅនឹងការចូលរួមពាក់ព័ន្ធណាមួយបន្ថែមទៀតរបស់ Stephen Heder នៅក្នុងសំណុំរឿង ០០៣ និង សំណើសុំឱ្យផ្តល់លទ្ធផលការងាររបស់ David Boyle, ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ ២០១៣។ ។ សំណើរបស់លោក មាស មុត សុំឱ្យផ្តល់លិខិតឆ្លើយឆ្លងពីប្រធានផ្នែកច្បាប់របស់ ក.ស.ច.ស ផ្ញើជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និង ឯកសារពាក់ព័ន្ធទាំងអស់ ព្រមទាំងសុំឱ្យដាក់ឯកសារនេះចូលទៅក្នុងសំណុំរឿង, ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ ២០១៣។ សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺថាតើ ក.ស.ច.ស ចាត់ទុកថាខ្លួនជាប់កាតព្វកិច្ចអនុវត្តយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ដែលថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ដែរឬទេ, ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣។ សំណើរបស់ មាស មុត សុំឱ្យ ក.ស.ច.ស ដាក់បញ្ចូលប្រតិចារិកទាំងមូលនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់ចូលទៅក្នុងសំណុំរឿង, ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣។ សំណើរបស់ មាស មុត សុំឱ្យផ្តល់លទ្ធផលការងាររបស់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ដែលពាក់ព័ន្ធនឹងនឹងការអនុវត្តន៍កិច្ចស៊ើបសួរមិនត្រឹមត្រូវក្នុងសំណុំរឿង ០០២, ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១៣។ សំណើរបស់ មាស មុត សុំឱ្យផ្តល់លក្ខណៈវិនិច្ឆ័យរបស់ ក.ស.ច.ស ពាក់ព័ន្ធនឹង “មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង បុគ្គលដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត”, ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣។ សំណើរបស់ មាស មុត ស្នើឱ្យ ក.ស.ច.ស បង្ខំ ក.ស.ព ឱ្យផ្តល់ឱ្យមេធាវីការពារក្តីនូវលក្ខណៈវិនិច្ឆ័យរបស់ខ្លួន ពាក់ព័ន្ធនឹង “មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង បុគ្គលដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត”, ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣។ សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺពាក់ព័ន្ធនឹងថាតើមេធាវីការពារក្តីអាចបើកកិច្ចស៊ើបសួរ នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះបានដែរ ឬ យ៉ាងណា, ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១៣។ ញត្តិរបស់ មាស មុត ប្រឆាំងនឹងការអនុវត្តបទល្មើសនានាដែលមានចែងក្នុងមាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (បទល្មើសតាមច្បាប់ជាតិ), ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣។ សំណើរបស់ មាស មុត ស្នើសុំ ក.ស.ច.ស ឱ្យសម្ភាសន៍សាក្សីសាជាថ្មី, ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣។ ញត្តិរបស់ មាស មុតប្រឆាំងនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣, ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣។

២៣. នៅថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត Harmon បានចេញដីកាសម្រេចចាប់បន្តកាលបរិច្ឆេទឡើងវិញសម្រាប់ដាក់ឯកសារនានា ស្តីពីទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់[32]។

២៤. នៅថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ បានដាក់ការឆ្លើយតបមួយច្បាប់ (ដែលចុះហត្ថលេខាដោយសហព្រះរាជអាជ្ញារង William Smith តែម្នាក់ឯងប៉ុណ្ណោះ)[33]។

២៥. នៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត Harmon បានផ្ញើលិខិតមួយច្បាប់ទៅមេធាវីការពារក្តីដោយបញ្ជាក់ថា គាត់បានទទួលសំណើសុំការពិចារណាទាំងនេះហើយ និង៖ "ដោយសារតែការជាប់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ ដែលត្រូវបានចោទប្រកាន់នៅក្នុង *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលស្នើសុំឱ្យច្រានចោលការតែងតាំងសហមេធាវីចាត់តាំង ដោយឈរលើមូលដ្ឋានទំនាស់ផលប្រយោជន៍មិនអាចផ្សះផ្សាបាន* (D56/1) នោះការដាក់ឯកសារនានាដូចបានលើកឡើងខាងលើ នឹងត្រូវបានដោះស្រាយក្នុងពេលវេលាមួយសមស្របដោយយោងតាមលទ្ធផលនៃសេចក្តីសម្រេចអំពីបញ្ហានេះ"[34]។

---

[32] ដីកាសម្រេចចាប់បន្តឡើងវិញនូវកាលបរិច្ឆេទសម្រាប់ដាក់ឯកសារ ស្តីពីបញ្ហាអត្ថិភាពនៃទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់នៅក្នុងការតំណាង មាស មុត, ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១៣, ឯកសារលេខ D56/14។

[33] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ ពាក់ព័ន្ធទៅនឹងទំនាស់ផលប្រយោជន៍របស់សហមេធាវីចាត់តាំង, ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៣, ឯកសារលេខ D56/15។

[34] លិខិតរបស់ ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តី, *សំណើសុំការពិចារណានានាដាក់ដោយសហមេធាវីចាត់តាំងនៅក្នុងសំណុំរឿង ០០៣*, ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១៣, ឯកសារលេខ D87។ នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត Harmon បានផ្ញើលិខិតមួយច្បាប់ដោយបញ្ជាក់ថា គាត់ក៏បានទទួលញត្តិរបស់ មាស មុត ប្រឆាំងនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III (JCE III) និង ញត្តិមួយផ្សេងទៀត ដែលសហចៅក្រមស៊ើបអង្កេតបានលុបចេញពីបញ្ជីនៅក្នុងលិខិតលើកទី ១ របស់គាត់។ លិខិតរបស់ ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តី, *ការកែប្រែ និង សេចក្តីបន្ថែមទៅលើលិខិតដែលមានចំណងជើងថា៖ "សំណើសុំការពិចារណានានាដាក់ដោយសហមេធាវីចាត់តាំងនៅក្នុងសំណុំរឿង ០០៣" ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១៣*, ឯកសារលេខ D87/1 ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១៣។

## III. ច្បាប់ និង ឧបករណ៍

### ក) អ.ជ.ក ជាស្ថាប័នរបស់ អ.វ.ត.ក ដែលមានតួនាទីសម្រេចលើបញ្ហាទំនាស់ផលប្រយោជន៍

២៦. លោក មាស មុត មានសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញកម្ពុជា[35] កិច្ចព្រមព្រៀង[36] ច្បាប់បង្កើត អ.វ.ត.ក[37] និង វិធានផ្ទៃក្នុង[38]

[35] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាតម្រូវឱ្យ អ.វ.ត.ក "ទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ"។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ដែលត្រូវបានសើរើដោយព្រះរាជក្រម ចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៩ ប្រកាសឱ្យប្រើវិសោធនកម្មមាត្រា ១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩៣ និង មាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩។ កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយគឺជាអត្ថបទមួយនៃអនុសញ្ញាបែបនេះ។ មាត្រា ១៤(៣)(ឃ) ចែងថា៖ "ក្នុងការសម្រេចចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ៖ ...ការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬ តាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន ..."។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានអនុម័ត និង បើកចំហរឱ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និង ទទួលស្គាល់ ដោយសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 2200A (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ដែលចូលជាធរមានកាលពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦ ស្របតាមមាត្រា ៤៩។

[36] មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") ចែងថា៖ "សិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយត្រូវតែគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ ជាពិសេស សិទ្ធិបែបនេះជាពិសេសរួមមាន៖ ... សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង ..."។

[37] មាត្រា ២៤ ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់បង្កើត អ.វ.ត.ក") ចែងថា៖ "ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវីដែលជ្រើសរើសដោយខ្លួនឯង ដោយខានមិនបាន ..."។ មាត្រា ៣៥ ថ្មី (ឃ) ចែងថា៖ "នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការការពារជាអប្បរមា និង ស្មើគ្នា ស្របតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ... ការពារខ្លួនដោយខ្លួនឯង ឬ តាមរយៈមេធាវីដែលជ្រើសរើសដោយខ្លួនឯង ..."។

[38] វិធាន ២១(១)(ឃ) ចែងថា៖ "ជនណាដែលត្រូវបានសង្ស័យ ឬ ដែលត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន

ដែលត្រូវទទួលបានជំនួយពីមេធាវី តាមជម្រើសរបស់គាត់ផ្ទាល់។ សហចៅក្រមស៊ើបអង្កេត Harmon បានបញ្ជាក់បន្ថែមថា បញ្ហានានាពាក់ព័ន្ធទៅនឹងទំនាស់ផលប្រយោជន៍ ត្រូវដោះស្រាយដោយ អ.គ.ក[39]។ "សេរីភាពក្នុងការជ្រើសរើសមេធាវី គឺជាសិទ្ធិសារវ័ន្តដែលអាចត្រូវដាក់កំហិតបាន តែនៅក្រោមកាលៈទេសៈមួយចំនួនដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់ ...។ ពាក់ព័ន្ធនឹងបញ្ហាបែបនេះ សហចៅក្រមស៊ើបអង្កេតគ្មានតួនាទីអ្វីដែលត្រូវគិតគូរ ឲ្យហួសពីការទទួលស្គាល់មេធាវីជាផ្លូវការ នៅពេលដែលលក្ខខណ្ឌតម្រូវទាំងអស់ត្រូវបានបំពេញនោះឡើយ"[40]។ ចំណុចនេះគឺស្របនឹងច្បាប់កម្ពុជាដែលកំណត់ថា គឺក្រុមប្រឹក្សាគណៈមេធាវីដែលជាអ្នកធ្វើសេចក្ដីសម្រេចបែបនេះ។ យោងតាមមាត្រា ១៩ នៃច្បាប់ស្ដីពីលក្ខន្តិកៈនៃគណៈមេធាវីកម្ពុជាចែងថា៖ "ក្រុមប្រឹក្សាគណៈមេធាវី ពិនិត្យដោះស្រាយគ្រប់បញ្ហាដែលពាក់ព័ន្ធទៅនឹងការអនុវត្តវិជ្ជាជីវៈមេធាវី"។

២៧. ចំណុចនេះក៏ស្របទៅនឹងច្បាប់ប្រទេសបារាំងផងដែរ។ នៅប្រទេសបារាំង ក៏ដូចជានៅប្រទេសកម្ពុជា ប្រធានគណៈមេធាវី (bâtonnier) ទទួលភារកិច្ចដោះស្រាយវិវាទខាងវិជ្ជាជីវៈ រវាងសមាជិកគណៈមេធាវី និង ស៊ើបអង្កេតលើបណ្ដឹងរបស់តតីយភាគី/រដ្ឋអាជ្ញា ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍។ មាត្រា ១៨៧ នៃ "ក្រិត្យច្បាប់លេខ ៩១-១១៩៧ ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ១៩៩១ ដែលរៀបចំវិជ្ជាជីវៈមេធាវី (ដាក់ ដាក់ឲ្យមានបច្ចុប្បន្នភាពនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៣) ចែងអំពីការស៊ើបអង្កេតទៅលើក្រមសីលធម៌វិជ្ជាជីវៈ ("ការស៊ើបអង្កេតក្រមវិជ្ជាជីវៈ") ដែលដឹកនាំដោយប្រធានគណៈមេធាវី។ មាត្រានេះចែងថា បន្ទាប់ពីមានការដាក់ពាក្យបណ្ដឹងដោយរដ្ឋអាជ្ញា ឬ អ្នកដាក់ពាក្យបណ្ដឹង ឬ ដោយគំនិតផ្ដួចផ្ដើមរបស់ខ្លួនផ្ទាល់ ប្រធានគណៈមេធាវីអាចបើកការស៊ើបសួរទៅលើបញ្ហាទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់។ ប្រធានគណៈមេធាវី មានអំណាចឥស្សរចិត្តសម្រេចថា មិនចាំបាច់មានការស៊ើបអង្កេតនោះឡើយ។ ក្រោយពីការបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួនរួចមក ប្រធានគណៈមេធាវី ឬ រដ្ឋអាជ្ញា អាចស្នើទៅក្រុមប្រឹក្សា

---

និង មានមេធាវីតាមការជ្រើសរើសរបស់ខ្លួន ហើយនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ត្រូវផ្ដល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប"។ វិធាន ២២(១) ចែងថា៖ "ជនណាដែលមានសិទ្ធិទទួលបានមេធាវីស្ថិតនៅក្រោមវិធាននេះ ត្រូវមានសិទ្ធិទទួលបានជំនួយពីមេធាវីជាតិ ឬ មេធាវីអន្តរជាតិ ដោយសហការជាមួយមេធាវីអន្តរជាតិ ទៅតាមការជ្រើសរើសដោយផ្ទាល់ខ្លួនរបស់ពួកគេ ..."។

[39] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, សេចក្ដីសម្រេចលើញត្តិ និង សារណាបន្ថែម ស្ដីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី, ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៣, ឯកសារលេខ D122/6 កថាខណ្ឌ ៧៨។

[40] *ដូចលេខយោងខាងលើ*, កថាខណ្ឌ ៧៧។

វិន័យនៃគណៈមេធាវី ដែលនឹងចេញសេចក្តីសម្រេចមួយ។ អំណាចស៊ើបអង្កេតរបស់ប្រធានគណៈមេធាវី ត្រូវបានបញ្ជាក់បន្ថែមដោយតុលាការកំពូល[41]។

២៨. លោក មាស មុត បានជ្រើសរើសសហមេធាវីរបស់គាត់ដោយសេរី។ អ.គ.ក បានពិចារណាទៅលើបញ្ហាថាតើទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់នេះ អាចរារាំងមិនឲ្យសហមេធាវីធ្វើជាតំណាងការពារលោក មាស មុត ដូចដែលច្បាប់កម្ពុជា និង វិធាន ៩ នៃបទបញ្ជារដ្ឋបាលសម្រាប់ អ.គ.ក បានតម្រូវដែរឬយ៉ាងណា។ ប្រធាន អ.គ.ក បានជួបលោក មាស មុត ដោយផ្ទាល់។ គាត់បានពិនិត្យឡើងវិញទៅលើការលះបង់សិទ្ធិ ស្តីពីទំនាស់ដែលអាចកើតមានឡើង។ គាត់បានរកឃើញថា ការលះបង់សិទ្ធិទាំងនេះត្រូវបានធ្វើឡើង "ដោយស្ម័គ្រចិត្ត ដោយបានដឹងឮជាមុន និង យ៉ាងច្បាស់លាស់"[42]។ ទីបំផុត គាត់រកឃើញថា គ្មានទំនាស់ផលប្រយោជន៍ដែលអាចបដិសេធមិនឲ្យសហមេធាវីធ្វើជាតំណាងការពារលោក មាស មុត នោះទេ។ អ.គ.ក មិនដែលត្រូវបានស្នើសុំឲ្យពិចារណាទៅលើសេចក្តីសម្រេចនេះឡើងវិញម្តងណាឡើយ។ នៅពេលធ្វើការសម្រេចចុងក្រោយរបស់ខ្លួនទៅលើភាពក្រីក្រ អ.គ.ក បានដឹងយ៉ាងពេញលេញអំពីការដាក់សារណាស្តីពីទំនាស់ផលប្រយោជន៍ ដោយអតីតសហព្រះរាជអាជ្ញាអន្តរជាតិ។ គ្រប់ការដាក់ឯកសារទាំងអស់ត្រូវបានចម្លងជូន អ.គ.ក។ ប៉ុន្តែ អ.គ.ក មិនបានចាត់វិធានការណាមួយដើម្បីពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួនឡើយ។ ផ្ទុយទៅវិញ ប្រធាន អ.គ.ក បានជម្រុញឲ្យសហចៅក្រមស៊ើបអង្កេត Harmon លើកចោលការហាមឃាត់មិនឲ្យមានការប្រាស្រ័យទាក់ទងគ្នា។

២៩. ពិតណាស់ថា ប្រសិនបើ អ.គ.ក យល់ឃើញថា ទំនាស់ផលប្រយោជន៍បានបដិសេធមិនឲ្យសហមេធាវីធ្វើជាតំណាងការពារឲ្យលោក មាស មុត មែននោះ ម្ល៉េះ អ.គ.ក នឹងបានចាត់វិធានការរួចទៅហើយ។ អ.គ.ក នៅតែមានសិទ្ធិអំណាចដើម្បីធ្វើការពិចារណាឡើងវិញ ទៅលើសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធទៅនឹងមេធាវីការពារក្តី ជាទង្វើមួយដែលលោក Endeley បានបង្ហាញ

---

[41] តុលាការកំពូល, សភារដ្ឋប្បវេណីទី១, ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១២, បណ្តឹងសាទុក្ខលេខ ១១-១៧.៩៩៩, ព្រឹត្តិប័ត្រឆ្នាំ ២០១២, I, លេខ ២០៣, ទិន្នន័យយុត្តិសាស្ត្រលេខ ២០១២-០២៣២៨៥។

[42] *សូមមើល* សំណើសុំការអនុញ្ញាតបង្កើនចំនួនទំព័រ និង សំណើសុំការពិចារណារបស់សហមេធាវី ស្តីពីទំនាស់ផលប្រយោជន៍ជាសក្តានុភូត ក្នុងការធ្វើជាតំណាងឲ្យលោក មាស មុត ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០១៣ ឯកសារលេខ D56/4/1 ឧបសម្ព័ន្ធ ក។

នៅក្នុងសំណុំរឿង ០០៤ ដោយតាមរយៈគំនិតផ្តួចផ្តើមរបស់គាត់ លុបឈ្មោះ[43] លោក Rogers ចេញពីបញ្ជីឈ្មោះមេធាវីបរទេសដែលមានសិទ្ធិគ្រប់គ្រាន់ និង ដកហូតការប្រឹក្សាច្បាប់ ដែល អ.គ.ក បានស្នើសុំសម្រាប់លោក Rogers ដោយសារតែ *នៅក្នុងចំណោមបញ្ហាជាច្រើនទៀត* លោក Endeley មានការព្រួយបារម្ភថា ទំនាស់ផលប្រយោជន៍អាចនឹងកើតមានឡើង[44]។

៣០. នៅក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេត Harmon បានកត់សម្គាល់ថា គាត់អាចពិនិត្យមើលឡើងវិញទៅលើសេចក្តីសម្រេចនានា ស្តីពីការតែងតាំងសហមេធាវី ក្នុងករណីមាន "ការជំទាស់តវ៉ាណាមួយ ដោយផ្អែកលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យជាសត្យានុម័ត ដូចជា ... អត្ថិភាពនៃទំនាស់ផលប្រយោជន៍"[45]។ ក្នុងការគាំទ្រដល់អំណះអំណាងនេះ សហចៅក្រមស៊ើបអង្កេត Harmon បានសម្អាងទៅលើករណីមួយរបស់ប្រទេសបារាំង នៅ*សាលាឧទ្ធរណ៍ទីក្រុងប៉ូ (Pau) សភាទី ១ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ១៩៩៨*។ សាលដីកាសាលាឧទ្ធរណ៍ថ្នាក់តំបន់នៃទីក្រុងប៉ូ ដែលត្រូវបានសម្រេចតម្កល់ទុកដោយតុលាការកំពូល[46]។ ប៉ុន្តែ បើពិនិត្យមើលករណីនេះឱ្យបានដិតដល់ទៅ ទោះបីជាករណីនេះអាចត្រូវបានយកមកអនុវត្តដោយផ្ទាល់ ជាប្រភពច្បាប់ចងកាតព្វកិច្ចនៅ អ.វ.ត.ក ក្តី ក៏បញ្ហាដែលមេធាវីការពារក្តីជំទាស់តវ៉ានេះ មិនគាំទ្រដល់អំណះអំណាង ដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត Harmon ដែលថា សហចៅក្រមស៊ើបអង្កេតមានសិទ្ធិអំណាចផ្នែកយុត្តាធិការ ដើម្បីពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចនានារបស់ អ.គ.ក ដែល

[43] យោងតាមសាវតានៃដីកាសម្រេចលើញត្តិ និង សារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី ក្នុងសំណុំរឿង ០០៤ លោក Endeley "បានបដិសេធមិនដាក់ឈ្មោះ [លោក Rogers] ចូលទៅក្នុងបញ្ជីឈ្មោះសហមេធាវីបរទេស"។ ប៉ុន្តែ អតីតមន្ត្រីទទួលបន្ទុក អ.គ.ក បានបញ្ជាក់រួចមកហើយថា ឈ្មោះរបស់លោក Rogers ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះមេធាវីហើយ។ *សូមមើល* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, សេចក្តីសម្រេចលើញត្តិ និង សារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៣ ឯកសារលេខ D122/6 កថាខណ្ឌ ២៥ និង កថាខណ្ឌ ៣៧។

[44] *ដូចលេខយោងខាងលើ* កថាខណ្ឌ ២៥ ដល់ ៣៧។

[45] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, សេចក្តីសម្រេចលើញត្តិ និង សារណាបន្ថែម ស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៣ ឯកសារលេខ D122/6 កថាខណ្ឌ ៨២។

[46] *ដូចលេខយោងខាងលើ* កំណត់សម្គាល់លេខ ៦៣ *ដែលដកស្រង់* សាលាឧទ្ធរណ៍ទីក្រុងប៉ូ (Pau), សភាទី១ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ១៩៩៨ ទិន្នន័យយុត្តិសាស្ត្រលេខ ១៩៩៨-៩៧០២៩៤ (ដែលត្រូវបានបញ្ជាក់បន្ថែមដោយសាលដីការបស់តុលាការកំពូលបារាំង សភារដ្ឋប្បវេណីទី ១ ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០០១ បណ្តឹងសាទុក្ខលេខ ៩៨-១៦៥០៨)។

ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ នោះទេ។

៣១. ករណីរបស់*សាលាឧទ្ធរណ៍ទីក្រុងប៉ូ អង្គជំនុំជម្រះទី ១ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ១៩៩៨* ត្រូវបានសម្រេចនៅក្រោមច្បាប់ចាស់ស្តីពីគណៈមេធាវី[47]។ ករណីនេះ គឺពាក់ព័ន្ធនឹងស្ថានភាពមួយដែលក្រុមហ៊ុនពាណិជ្ជកម្មមួយបានដាក់ញត្តិជូនគណៈមេធាវីទីក្រុងប៉ូ ដោយចោទប្រកាន់ថា មានទំនាស់ផលប្រយោជន៍ បន្ទាប់ពីមេធាវីរបស់ក្រុមហ៊ុន បានធ្វើជាតំណាងការពារឱ្យអតីតប្រធានរបស់ខ្លួន នៅក្នុងកិច្ចដំណើរការនីតិវិធីមុនៗ ទាក់ទងទៅនឹងបញ្ហាដែលក្រុមហ៊ុនពាណិជ្ជកម្មបានចោទប្រកាន់ថា ប្រធានក្រុមហ៊ុនរូបនេះបានបង្កព្យសនកម្មដល់ក្រុមហ៊ុន។ ប្រធានគណៈមេធាវីទីក្រុងប៉ូ បានចេញសេចក្តីជូនដំណឹងក្នុងការដាក់ញត្តិជូនក្រុមប្រឹក្សាវិន័យ[48] ប៉ុន្តែ ពុំមានការចាត់វិធានការណាមួយអស់រយៈពេលជាច្រើនខែ។ បន្ទាប់មក ក្រុមហ៊ុនពាណិជ្ជកម្ម បានដាក់បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងបញ្ហានេះ ដើម្បីទទួលបានចៅក្រមចាត់របៀប (emergency judge/Juge des référés)។ សាលាឧទ្ធរណ៍ថ្នាក់តំបន់នៃទីក្រុងប៉ូបានសម្រេចថា ចៅក្រមចាត់របៀបមានយុត្តាធិការក្នុងករណីដែលនីតិវិធីធម្មតានៅចំពោះមុខគណៈមេធាវីនេះមិនមានអានុភាព។ សេចក្តីសម្រេចនេះត្រូវបានតម្កល់ទុកដោយតុលាការកំពូល[49]។ ករណីនេះ គឺខុសគ្នាពីស្ថានភាពបច្ចុប្បន្ន។ អតីតសហព្រះរាជអាជ្ញាអន្តរជាតិ ជាបឋមមិនបានលើកអំពីបញ្ហាទំនាស់ផលប្រយោជន៍នេះជាមួយនឹង អ.គ.ក ឬ គណៈមេធាវីនោះទេ។ មិនមានភស្តុតាងបង្ហាញថា នីតិវិធីនៃការតែងតាំងរបស់ អ.គ.ក គ្មានអានុភាពនោះទេ។ មិនមានអ្វីបញ្ជាក់ថា អ.គ.ក មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅក្នុងការពិចារណាលើទំនាស់ផលប្រយោជន៍ជាសក្តានុភូតណាមួយ នៅពេលចាត់តាំងមេធាវីការពារក្តីនោះទេ។

---

[47] *នៅក្នុងចំណោមមាត្រាជាច្រើន* ករណីនេះយោងមាត្រា ៨០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង មាត្រា ១៥៥ នៃក្រឹត្យ ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ១៩៩១ ។ ក្នុងពេលដំណាលគ្នានេះដែរ មាត្រាទាំងនេះសំដៅលើទំនាស់ផលប្រយោជន៍។ បច្ចុប្បន្ននេះ មាត្រាទាំងនេះ គឺជាមាត្រា ៤.១ នៃវិធានជាតិដែលអាចអនុវត្តចំពោះវិជ្ជាជីវៈមេធាវី ("វិធានផ្ទៃក្នុងជាតិស្តីពីវិជ្ជាជីវៈមេធាវី– RIN") និង មាត្រា ៧ នៃក្រឹត្យលេខ ២០០៥-៧៩០, ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០០៥ ទាក់ទងនឹងវិធាននៃក្រមសីលធម៌វិជ្ជាជីវៈមេធាវី ច្បាប់ដែលត្រូវបានដាក់ឱ្យមានបច្ចុប្បន្នភាពនៅថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០១១ ("ក្រឹត្យ ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០០៥")។

[48] (Conseil de l'Ordre) គឺជាអតីតស្ថាប័នដាក់វិន័យ មុនពេលក្រុមប្រឹក្សាវិន័យត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៤។ ក្រុមប្រឹក្សាវិន័យនេះត្រូវបានបង្កើតឡើងដោយច្បាប់លេខ ២០០៤-១៣០ ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៤ និង ក្រឹត្យលេខ ២០០៥-៥៣១ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៥។

[49] តុលាការកំពូល សភារដ្ឋប្បវេណីទី ១ ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០០១ បណ្តឹងសាទុក្ខលេខ ៩៨-១៦.៥០៨។

**ខ) ទន្លីករណ៍របស់អតីតសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតលើបញ្ហាទំនាស់ផលប្រយោជន៍ គឺជាការភាន់ច្រឡំ**

៣២. អតីតសហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានយុត្តាធិការពិចារណាទៅលើសំណើរបស់ Cayley "ទោះបីជា *បណ្តឹងឧទ្ធរណ៍* អនុលោមតាមវិធាន ១១(៦) នៃវិធានផ្ទៃក្នុងក្តី ឬ ជា *សំណើដាច់ដោយឡែក* ក្តី ដែលពាក់ព័ន្ធនឹងការអនុវត្តយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការទទួលយក ឬ ដកហូតមេធាវីនៅចំពោះមុខ អ.វ.ត.ក ដោយអនុលោមតាមវិធាន ២១(១) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា ដោយអានរួមគ្នាជាមួយនឹងមាត្រា ៦.២ និង ៧.៤ នៃបទបញ្ជាផ្ទៃករដ្ឋបាលរបស់ អ.គ.ក"[50]។ ពុំមានលទ្ធភាពណាមួយ ក្នុងចំណោមលទ្ធភាពទាំងពីរ ផ្តល់យុត្តាធិការឲ្យសហចៅក្រមស៊ើបអង្កេតសម្រេចលើបញ្ហាទំនាស់ផលប្រយោជន៍ ដែលត្រូវបានចោទប្រកាន់នេះទេ។

**១) ភាពអាចទទួលយកបានជាបណ្តឹងឧទ្ធរណ៍ ស្របតាមវិធាន ១១(៦)**

៣៣. វិធាន ៧៤(២) ចែងថា៖ "សហព្រះរាជអាជ្ញា អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត"។ អង្គបុរេជំនុំជម្រះបានលើកឡើង (នៅពេលពិចារណា ថាតើសហព្រះរាជអាជ្ញាអន្តរជាតិមានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ដែលបង្គាប់ឲ្យគាត់ដកវិញនូវសេចក្តីប្រកាសព័ត៌មានជាសាធារណៈ ដែលបានធ្វើឡើងទាក់ទងនឹងសំណុំរឿង ០០៣) ថា វិធាននេះ *គ្រាន់តែ* អនុញ្ញាតឲ្យ ក.ស.ព ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ដែលទាក់ទងនឹងការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌប៉ុណ្ណោះ[51]។ នៅក្នុងសេចក្តីសម្រេចមួយផ្សេងទៀតក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះ បានលើកឡើងថា៖

> តួនាទីរបស់ព្រះរាជអាជ្ញា មិនចាំបាច់ពង្រីករហូតដល់ករណីទាក់ទងនឹងទង្វើ ដែលមានចែងក្នុងវិធាន ៣៥ និង វិធាន ៣៨ នៃវិធានផ្ទៃក្នុង [ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់

---

[50] សំណើរបស់ Cayley កថាខណ្ឌ ៨ (មានបញ្ជាក់បន្ថែមនៅក្នុងសំណើច្បាប់ដើម)។

[51] "អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា នៅពេលពិនិត្យទៅលើបរិបទ និងព្រមទាំងពិចារណាជាមួយនឹងវិធាន ៧៣ នៃវិធានផ្ទៃក្នុង វាបានបង្ហាញយ៉ាងច្បាស់ថា វិធាន ៧៤(២) បានប្រមើលមើលទុកជាមុននូវសិទ្ធរបស់សហព្រះរាជអាជ្ញា ក្នុងការប្តឹងឧទ្ធរណ៍ទៅលើដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលពាក់ព័ន្ធទៅនឹងកិច្ចស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ"។ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ D14/1/3 កថាខណ្ឌ ១៦។

អង្គជំនុំជម្រះ និង កំហុសវិជ្ជាជីវៈរបស់មេធាវី] នោះទេ។ តួនាទីរបស់សហព្រះរាជអាជ្ញានៃ អ.វ.ត.ក តាមវិធានផ្ទៃក្នុង *គឺកំណត់ដាច់ខាត* ត្រឹមតែរឿងក្តីដែលកំពុងចាត់ការ និង ការស៊ើបអង្កេតលើបទល្មើសក្រោមយុត្តាធិការរបស់ អ.វ.ត.ក ...។ អង្គបុរេជំនុំជម្រះយល់ឃើញថា តួនាទីរបស់សហព្រះរាជអាជ្ញាមិនត្រូវបានពង្រីកដោយស្វ័យប្រវត្តិ រហូតដល់នីតិវិធីទាក់ទងនឹងការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ និង/ឬ កំហុសវិជ្ជាជីវៈរបស់មេធាវី នោះទេ[52]។

៣៤. វិធាន ១១(៦) មិនបានចែងបញ្ជាក់ច្បាស់លាស់ថា អនុលោមតាមវិធាននេះ អ្នកណាអាចមានសិទ្ធិប្តឹងឧទ្ធរណ៍បាននោះទេ។ វិធាននេះគ្រាន់តែចែងថា៖

ប្រធានអង្គភាពគាំពារការការពារក្តី *ត្រូវសម្រេចអំពីជនណាមួយជាជនក្រីក្រ និង ការចាត់តាំង*

---

[52] *ករណីរបស់ នួន ជា និង ជនជាប់ចោទដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ)៖ សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារលេខ D138/1/8 កថាខណ្ឌ ១៣-១៤ (មានបញ្ជាក់បន្ថែម)។ អង្គបុរេជំនុំជម្រះបានពន្យល់ស្រដៀងគ្នានេះថា តួនាទីរបស់ ក.ស.ព ត្រូវបានកំណត់នៅក្នុងស្ថានភាពផ្សេងទៀត ដែលមិនពាក់ព័ន្ធនឹងរឿងក្តីដែលកំពុងចាត់ការ និង ការស៊ើបអង្កេតបទល្មើសដែលស្ថិតនៅក្រោមយុត្តាធិការរបស់អ.វ.ត.ក នោះឡើយ។ *សូមមើល* សំណុំរឿងលេខ ០០២/១៤-១២-២០០៩-អ.វ.ត.ក/អ.ប.ជ(០៨) សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលដាក់ចម្លើយតបទៅនឹងសំណើរបស់ អៀង សារី សុំឲ្យចាត់ចំណាត់ថ្នាក់ឯកសារ អ.ប.ជ ០៨ ទាំងអស់ជាឯកសារសាធារណៈ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០១១ កថាខណ្ឌ ៤។ សំណុំរឿងលេខ ០០២/១១-១២-២០០៩-អ.វ.ត.ក(អ.ប.ជ០៧) សាលដីកាលើពាក្យបណ្តឹងរបស់ អៀង សារី និង អៀង ធីរិទ្ធ តាមវិធានផ្ទៃក្នុង ៣៤ ប្តឹងជំទាស់ចៅក្រម Marcel Lemonde ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ឯកសារលេខ ៦ កថាខណ្ឌ ២០៖ "អង្គបុរេជំនុំជម្រះពិចារណាឃើញថា សហព្រះរាជអាជ្ញាមិនមានសិទ្ធិនៅក្នុងប្រភេទបណ្តឹង [ដែលទាក់ទងនឹងបណ្តឹងជំទាស់ចៅក្រម ដោយសារតែភាពលំអៀងដែលបានចោទប្រកាន់] បែបនេះឡើយ"។ កាលពីមុន ក.ស.ព ខ្លួនឯងបានទទួលស្គាល់រួចមកហើយអំពីតួនាទីមានកម្រិតរបស់ខ្លួននៅក្នុងស្ថានភាពបែបនេះ (នៅក្នុងបរិបទនៃចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការព្រមានរបស់ ក.ស.ច.ស)៖ "បញ្ហានៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងការប្រមាថ នៅក្នុងយុត្តាធិការជាតិ និង អន្តរជាតិមួយចំនួន គឺជាបញ្ហាដែលច្រើនតែមានរវាងតុលាការ និង ជនល្មើសដែលត្រូវបានចោទប្រកាន់។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាមិនចាត់ទុកខ្លួនឯងថាជាគូភាគីពេញលេញនៃដំណើរការនីតិវិធីទាំងនេះទេ ប៉ុន្តែ គ្រាន់តែជា "ភាគីដែលមានចំណាប់អារម្មណ៍" ដែលជាមន្ត្រីនៃតុលាការនេះតែប៉ុណ្ណោះ"។ *ករណីរបស់ នួន ជា និង ជនជាប់ចោទដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ)៖ សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ដែលជំទាស់ទៅនឹងដីកាសម្រេចសម្ងាត់របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០០៩ ឯកសារលេខ D138/1/5 កថាខណ្ឌ ៥។

*មេធាវីការពារជនក្រីក្រ* ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលកំណត់នៅក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី។ សេចក្តីសម្រេចនេះបើកផ្លូវប្តឹងតវ៉ាទៅសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ដោយយោងទៅតាមករណី ដែលជននោះត្រូវចូលបង្ហាញខ្លួនក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចនេះ។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬ របស់អង្គជំនុំជម្រះ ក្នុងករណីនេះបិទផ្លូវប្តឹងតវ៉ា[53]។

៣៥. វិធាននេះមានបំណងផ្តល់ឲ្យ *បុគ្គលដែលអះអាងអំពីភាពក្រីក្រ* នូវសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងសេចក្តីសម្រេចនានារបស់ អ.គ.ក។ វិធាននេះ *មិនមាន* បំណងផ្តល់សិទ្ធិឲ្យ ក.ស.ព ប្តឹងឧទ្ធរណ៍នោះទេ។ វិធាននេះអនុវត្តចំពោះតែសេចក្តីសម្រេចនានា លើការចាត់តាំងមេធាវីការពារជនក្រីក្រតែប៉ុណ្ណោះ។ ប្រសិនបើលោក មាស មុត *មិនមែនជា* ជនក្រីក្រទេនោះ អនុលោមតាមវិធាននេះ អតីតសហព្រះរាជអាជ្ញា Cayley ក៏មិនមានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចតែងតាំងសហមេធាវីនេះដែរ។ វាមិនសមហេតុផលនោះទេ ចំពោះការលើកឡើងថា សិទ្ធិរបស់ ក.ស.ព ក្នុងការប្តឹងឧទ្ធរណ៍ក្នុងបញ្ហាទំនាស់ផលប្រយោជន៍ គឺអាស្រ័យទៅតាមភាពក្រីក្ររបស់លោក មាស មុត នោះ។

៣៦. បញ្ហាទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់នេះ *មិនមែន* ជាបញ្ហាដែលជាប់ទាក់ទងខ្លាំងទៅនឹងរឿងក្តីដែលកំពុងតែបន្ត ឬ ការស៊ើបអង្កេតទៅលើបទល្មើស ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក នោះទេ។ វិធាន ១១(៦) មិនមានបំណងផ្តល់សិទ្ធិប្តឹងឧទ្ធរណ៍ដល់ ក.ស.ព នោះទេ។ ដូច្នេះ អតីតសហព្រះរាជអាជ្ញាអន្តរជាតិ Cayley មិនមានសិទ្ធិលើកយកបញ្ហានេះមកដាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដូចជាតាមរយៈបណ្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ១១(៦) នោះឡើយ។

**២) ភាពអាចទទួលយកបានជា "សំណើដាច់ដោយឡែក"**

៣៧. ដើម្បីជាជម្រើសដល់ភាពអាចទទួលយកបានជាបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន១១(៦) អតីតសហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានជំទាស់តវ៉ាថា សហចៅក្រមស៊ើបអង្កេតអាចទទួលបន្ទុកយុត្តាធិការលើសេចក្តីសម្រេចអំពីទំនាស់ផលប្រយោជន៍ ដោយឈរលើមូលដ្ឋាន "សំណើដាច់ដោយឡែក" ពាក់ព័ន្ធនឹងការអនុវត្តយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការទទួលយក និង ដកហូតមេធាវីនៅចំពោះមុខ អ.វ.ត.ក អនុលោមតាមមាត្រា ២១(១) នៃកិច្ចព្រមព្រៀង

[53] មានបញ្ជាក់បន្ថែម។

អានរួមគ្នាជាមួយមាត្រា ៦.២ និង ៧.៤ នៃបទបញ្ជារដ្ឋបាលសម្រាប់ អ.គ.ក។ ទឡ្ហីករណ៍នេះក៏មិនអាចទទួលយកបានដូចគ្នា។

៣៨. ដូចបានពិភាក្សាខាងលើរួចមកហើយ អង្គបុរេជំនុំជម្រះបំភ្លឺថា ក.ស.ព អាចប្តឹងឧទ្ធរណ៍តែទៅលើបញ្ហាទាក់ទងនឹងរឿងក្តីដែលកំពុងតែបន្ត ឬ ការស៊ើបអង្កេតលើបទល្មើសដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក តែប៉ុណ្ណោះ។ ស្រដៀងគ្នានេះដែរ ក.ស.ព គួរត្រូវបានដាក់កម្រិតចំពោះការលើកឡើងនូវ "សំណើដាច់ដោយឡែក" ជូន ក.ស.ច.ស ដោយសារតែសំណើបែបនេះមិនជាប់ទាក់ទងខ្លាំងទៅនឹងរឿងក្តីដែលកំពុងតែបន្ត ឬ ការស៊ើបអង្កេតលើបទល្មើសនោះទេ។

៣៩. មាត្រា ២១(១) នៃកិច្ចព្រមព្រៀង ក៏ដូចជាមាត្រា ៤២(៣) នៃច្បាប់បង្កើត អ.វ.ត.ក (មិនត្រូវបានដកស្រង់ដោយអតីតសហព្រះរាជអាជ្ញាអន្តរជាតិ Cayley នោះទេ) គ្រាន់តែនិយាយសំដៅទៅលើ "មេធាវីការពារក្តីរបស់ជនសង្ស័យ ឬ ជនជាប់ចោទ *ដែលត្រូវបានទទួលស្គាល់បែបនេះដោយអង្គជំនុំជម្រះវិសាមញ្ញ*..."[54]។ មាត្រា ២១(១) នៃកិច្ចព្រមព្រៀង*មិនបាន*ចែងថា ស្ថាប័នណាមួយនៃ អ.វ.ត.ក ជាអ្នកទទួលខុសត្រូវចំពោះការទទួលស្គាល់សហមេធាវីនោះឡើយ។ ផ្ទុយទៅវិញ វិធាន ១១ ចែងច្បាស់ថាគឺ អ.គ.ក ជាអ្នកទទួលខុសត្រូវក្នុងការកំណត់អំពីលក្ខណៈវិនិច្ឆ័យ និង នីតិវិធីសម្រាប់ចាត់តាំងសហមេធាវី និង រក្សាទុកបញ្ជីឈ្មោះសហមេធាវីដែលពេញលក្ខណៈ និង ការទាក់ទងជាមួយសហមេធាវីទាំងនោះ។ វាជាការលើកឡើងតែមួយគត់របស់វិធាន ១១ អំពីស្ថាប័នដទៃទៀតរបស់តុលាការនេះ (ក្រៅពីវិធាន ១១(៦) ដែលបានពិភាក្សាខាងលើរួចមកហើយ) ពាក់ព័ន្ធនឹងការបង្ហាញបញ្ជីឈ្មោះសហមេធាវីដែលពេញលក្ខណៈសម្រាប់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ[55] និង យុត្តាធិការរបស់អង្គបុរេជំនុំជម្រះក្នុងការពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនានា ដែលមិនដាក់ឈ្មោះសហមេធាវីទៅក្នុងបញ្ជី [ក្នុងវិធាន ១១(៥)]។ វិធានផ្សេងទៀត ដូចជា វិធាន ៨១(៥) គឺសំដៅទៅលើមេធាវីចាត់តាំងដោយ អ.គ.ក ហើយមិនមានចែងអំពីលក្ខខណ្ឌតម្រូវឲ្យមានការបញ្ជាក់បន្ថែមការចាត់តាំងនេះដោយ ក.ស.ច.ស ឬ ដោយអង្គជំនុំជម្រះឡើយ។

---

[54] មានបញ្ជាក់បន្ថែម។

[55] វិធាន ១១(២)(ង) ចែងថា អ.គ.ក នឹង៖ "ដោយស្ថិតនៅក្រោមការឃ្លាំមើលរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមករណីសមស្រប បង្ហាញបញ្ជីឈ្មោះមេធាវី ... ទៅដល់បុគ្គលដែលមានសិទ្ធិទទួលបានមេធាវីការពារក្តី ..."។

៤០. ការលើកឡើងអំពីលក្ខខណ្ឌតម្រូវឱ្យមានការបញ្ជាក់បន្ថែមនូវការតែងតាំងមេធាវី ត្រូវបានរកឃើញតែនៅក្នុងបទបញ្ជារដ្ឋបាលសម្រាប់ អ.គ.ក ផ្ទាល់តែប៉ុណ្ណោះ។ មាត្រា ៦.២ ចែងថា អ.គ.ក ត្រូវ "បញ្ជូនទម្រង់លេខ ៧ ស្តីពីសំណើសុំជ្រើសរើស/ចាត់តាំងសហមេធាវី ទៅចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះពាក់ព័ន្ធ ដើម្បីចេញដីកាបញ្ជាក់បន្ថែមលើការចាត់តាំងមេធាវីបណ្តោះអាសន្ន ដែលត្រូវដាក់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញ ដូចមានកំណត់នៅក្នុងមាត្រា ២១(១)នៃកិច្ចព្រមព្រៀង"។ បទបញ្ជារដ្ឋបាលនេះមិនមានចែងអំពីលទ្ធភាពនៃការបដិសេធការចាត់តាំងនេះទេ។ បទបញ្ជារដ្ឋបាលនេះកំណត់អំពីបញ្ញត្តិនីតិវិធីសាមញ្ញមួយ ហើយមិនបានផ្តល់យុត្តាធិការឱ្យសហចៅក្រមស៊ើបអង្កេត បដិសេធសេចក្តីសម្រេចរបស់ អ.គ.ក អំពីការតែងតាំងមេធាវីនោះឡើយ។

៤១. មាត្រា ២១(១) នៃកិច្ចព្រមព្រៀងមិនមែនជាមូលដ្ឋានសម្រាប់ការធ្វើ "សំណើដាច់ដោយឡែក" ទៅសហចៅក្រមស៊ើបអង្កេតនោះទេ។ វិធាននៃផ្ទៃក្នុងចែងថា អ.គ.ក មានភារកិច្ចទទួលខុសត្រូវលើនីតិវិធីតែងតាំងមេធាវី។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេត មិនអាចទទួលបន្ទុកយុត្តាធិការដោយឈរលើមូលដ្ឋាន "សំណើដាច់ដោយឡែក" ដែលធ្វើឡើងដោយអតីតសហព្រះរាជអាជ្ញាអន្តរជាតិ Cayley នោះឡើយ។

## II. សេចក្តីសន្និដ្ឋាន និង សំណូមពរ

៤២. សហចៅក្រមស៊ើបអង្កេត មិនមានយុត្តាធិការពិចារណាទៅលើសំណើរបស់ Cayley នោះទេ។ អ.គ.ក ត្រូវបានសុំឱ្យសម្រេចថា តើមានទំនាស់ផលប្រយោជន៍ណាមួយ ដែលអាចរារាំងមិនឱ្យសហមេធាវីធ្វើជាតំណាងឱ្យលោក មាស មុត ដែរឬទេ។ ក្រោយពីការពិចារណាទៅលើបញ្ហានេះយ៉ាងល្អិតល្អន់រួចមក លោក Endeley បានសម្រេចតែងតាំងសហមេធាវីទាំងពីរ។ គាត់មិនដែលបានពិចារណាអំពីជំហរនេះឡើងវិញនោះទេ ទោះបីជាគាត់បានដឹងយ៉ាងពេញលេញអំពីជំហររបស់អតីតសហព្រះរាជអាជ្ញាអន្តរជាតិក៏ដោយ។ អតីតសហព្រះរាជអាជ្ញាអន្តរជាតិមិនមានសិទ្ធិប្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចរបស់ អ.គ.ក នៅចំពោះមុខ ក.ស.ច.ស ដោយអនុលោមតាមវិធាន ១១(៦) នោះទេ ហើយ ក.ស.ច.ស ក៏មិនអាចទទួលបន្ទុកយុត្តាធិការពិចារណាទៅលើ "សំណើដាច់ដោយឡែក" នេះ ដោយអនុលោមតាមមាត្រា ២១(១) នៃកិច្ចព្រមព្រៀងនោះដែរ។

៤៣. សហចៅក្រមស៊ើបអង្កេត Harmon បានរកឃើញថា សហចៅក្រមស៊ើបអង្កេតមិនមានតួនាទីអ្វីក្រៅតែការទទួលស្គាល់សហមេធាវីជាផ្លូវការនោះឡើយ នៅពេលដែលលក្ខខណ្ឌតម្រូវទាំងអស់ត្រូវបានបំពេញចប់សព្វគ្រប់ហើយនោះ។ សហចៅក្រមស៊ើបអង្កេត មិនត្រូវផ្តល់សេចក្តីគោរព

ចំពោះសេចក្តីសម្រេចរបស់ អ.គ.ក ពាក់ព័ន្ធទៅនឹងមេធាវីការពារក្តីក្នុងសំណុំរឿង ០០៤ ច្រើនជាងការផ្តល់សេចក្តីគោរពចំពោះសេចក្តីសម្រេចបែបនេះនៅក្នុងសំណុំរឿង ០០៣ នោះទេ។ ទង្វើបែបនេះអាចនឹងរំលោភលើសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការប្រព្រឹត្តដូចៗគ្នា[56]។

**ហេតុដូច្នេះ** ដោយយោងទៅលើសម្អាងហេតុដូចបានបញ្ជាក់ជូនខាងលើ មេធាវីការពារក្តីសូមគោរពស្នើឲ្យសហចៅក្រមស៊ើបអង្កេត៖

[56] លោក មាស មុត មានសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការប្រព្រឹត្តដូចៗគ្នានៅចំពោះមុខច្បាប់។ សិទ្ធិនេះត្រូវបានធានាឲ្យគាត់តាមរយៈ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលចែងនៅត្រង់ផ្នែកមួយថា៖ “ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់..”។ សិទ្ធិនេះក៏មានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែល អ.វ.ត.ក ត្រូវតែគោរពតាម អនុលោមតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ១២(២) នៃកិច្ចព្រមព្រៀង និង មាត្រា ៣៣ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក។ មាត្រា ៧ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងនៅត្រង់ផ្នែកមួយថា៖ “មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និង មានសិទ្ធិទទួលបានការការពារពីច្បាប់ ដោយគ្មានការរើសអើង។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការការពារស្មើៗគ្នា ប្រឆាំងនឹងការរើសអើងណាដែលរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឲ្យមានការរើសអើង”។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់មហាសន្និបាតលេខ 217A (III) ឯកសារ អ.ស.ប លេខ A/810 ត្រង់កថាខណ្ឌ ៧១ (១៩៤៨)។ មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ចែងថា៖ “ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និង សាលាជម្រះក្តី”។ មាត្រា ២៦ ចែងនៅត្រង់ផ្នែកមួយថា៖ “ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និង មានសិទ្ធិការការពារពីច្បាប់ស្មើគ្នាដោយឥតរើសអើង”។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលត្រូវបានអនុម័ត និង បើកឲ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និង ចូលជាសមាជិក តាមរយៈសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 2200A (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ដែលចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦ ស្របតាមមាត្រា ៤៩ មាត្រា ១៤(១) និង មាត្រា ២៦។ សិទ្ធិនេះក៏ត្រូវបានចែងនៅក្នុងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) និង លក្ខណៈពិសេសៗដែលលេចឡើងនៅក្នុងលិខិតុបករណ៍ថ្នាក់តំបន់ និង រដ្ឋធម្មនុញ្ញរបស់បណ្តាប្រទេសជាច្រើន។ *សូមមើល* មាត្រា ២១(១) នៃលក្ខន្តិកៈសម្រាប់តុលាការ ICTY ។ ពិធីសារលេខ ១២ នៃអនុសញ្ញាទ្វីបអឺរ៉ុបសម្រាប់ការការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន។ មាត្រា ២៤ នៃអនុសញ្ញាអន្តរអាមេរិកកាំងស្តីពីសិទ្ធិមនុស្ស ។ រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកវិសោធនកម្មលើកទី ១៤។ មាត្រា ១ នៃរដ្ឋធម្មនុញ្ញាប្រទេសបារាំង ដែលត្រូវបានអនុម័តក្នុងឆ្នាំ ១៩៥៨ ។ មាត្រា ៧ នៃរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋសហព័ន្ធអូទ្រីស ។ មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប៉ូឡូញ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៧។ សិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការប្រព្រឹត្តស្មើគ្នានៅចំពោះមុខ អ.វ.ត.ក នឹងត្រូវបានរំលោភដោយការប្រព្រឹត្តមកលើរូបគាត់ខុសគ្នាពីជនសង្ស័យក្នុងសំណុំរឿង ០០៤ ដោយពិចារណាឃើញថា បញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងករណីនីមួយៗមានលក្ខណៈស្រដៀងគ្នាបំផុត គឺ សិទ្ធិអំណាចរបស់ ក.ស.ច.ស ទៅលើសេចក្តីសម្រេចនានារបស់ អ.គ.ក ពាក់ព័ន្ធនឹងមេធាវីការពារក្តី។

**ក. ពិចារណា/ពិចារណាឡើងវិញ** ថាតើសហចៅក្រមស៊ើបអង្កេតមានយុត្តាធិការសម្រេចលើបញ្ហាទំនាស់ផលប្រយោជន៍ ដែរឬទេ និង

**ខ. សម្រេចថា** សហចៅក្រមស៊ើបអង្កេត មិនមានយុត្តាធិការសម្រេចលើសំណើរបស់ Cayley នោះទេ។

សូមទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៦** ខែ**វិច្ឆិកា** ឆ្នាំ **២០១៣**

សហមេធាវីការពារក្តីរបស់ មាស មុត

អាង ឧត្តម　　　　Michael G. KARNAVA